**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកិច្ចការនារី**

លេខ ១៩៤០ កកន / សជណ

ថ្ងៃព្រហស្បតិ៍ ៣ កើត ខែ កត្ដិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០១៩

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការរៀបចំ និងបង្កើតបណ្ដាញសហគ្រិនស្ដ្រីនៅកម្ពុជា

ក្រសួងកិច្ចការនារី សូមជម្រាបជូនដំណឹងដល់ *លោកជំទាវ ឯកឧត្ដម អ្នកឧកញ៉ា លោកឧកញ៉ា លោកស្រី លោក* ដែលជាប្រធានសហព័ន្ធ សមាគម អង្គភាព បណ្ដាញសហគ្រិនសហគ្រាសខ្នាតមីក្រូ តូច និងមធ្យមនៅកម្ពុជា ឱ្យបានជ្រាបថា៖ ស្របតាមស្ថានភាពកើនឡើងនៃការចូលរួមរបស់ស្ដ្រី នៅក្នុងវិស័យធុរៈកិច្ច និងវិស័យសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម ក្រសួងកិច្ចការនារីបានពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័ន ដែលគូពាក់ព័ន្ធ និងវិស័យឯកជន ក្នុងការដឹកនាំសម្របសម្រួលរៀបចំនិងបង្កើត*បណ្ដាញសហគ្រិនស្ដ្រីនៅកម្ពុជា (Cambodia Women Entrepreneurs' Network, CamWEN)* ក្នុងគោលបំណងដើម្បីប្រមូលផ្ដុំសម្លេង និងភាពជាតំណាងរបស់ស្ដ្រីនៅក្នុងវិស័យទាំងនេះ ប្រកបដោយគុណភាព និងបរិយាប័ន្ន ឈានទៅលើកកម្ពស់ការអភិវឌ្ឍសហគ្រិនភាពស្ដ្រី។ បណ្ដាញនេះនឹងដឹកនាំដោយតំណាងសហព័ន្ធ សមាគម ក្រុម ឬបណ្ដាញសហគ្រិននៃសហគ្រាសខ្នាតមីក្រូ តូច និងមធ្យមរាជធានី ខេត្ត។

ឆ្លើយតបនឹងចំណុចខាងលើនេះ ក្រសួងកិច្ចការនារី សូមលើកទឹកចិត្តដល់តំណាងសមាគម សហព័ន្ធ និងបណ្ដាញសហគ្រិនទាំងអស់ អញ្ជើញចូលរួម ក្នុងការបង្កើតនិងដំណើរការបណ្ដាញនេះ ស្របតាមលក្ខខណ្ឌ ចំណុចណាមួយ ក្នុងចំណោមចំណុច ដូចខាងក្រោម ៖

- តំណាងឱ្យ*ក្រុម សហព័ន្ធ ឬសមាគមស្ដ្រី* ក្នុងវិស័យធុរៈកិច្ច សហគ្រាសខ្នាតមីក្រូ តូច និងមធ្យមនៅកម្ពុជា ដែលមានសមាជិករបស់ខ្លួន យ៉ាងតិច២៥នាក់។
- តំណាងឱ្យ*ក្រុម សហព័ន្ធ សហគមន៍ ឬសមាគមសហគ្រិន និងធុរៈកិច្ចនានា*នៅកម្ពុជា ដែលមានសមាជិកជាស្ដ្រី យ៉ាងតិច៥០នាក់ ។

បណ្ដាញជាតិនេះ គ្រោងនឹងដំណើរការ នៅចុងឆ្នាំ២០១៩ ។ អគ្គនាយកដ្ឋានសមភាពយេនឌ័រ និងអភិវឌ្ឍន៍សេដ្ឋកិច្ច នៃក្រសួងកិច្ចការនារី នឹងចាប់ទទួល ពាក្យស្នើសុំចូលជាសមាជិកបណ្ដាញ ពីពេលនេះតទៅរហូតដល់ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៩ តាមរយៈ អ៊ីម៉ែល sithonsoth@yahoo.com។

សូមភ្ជាប់ជូននូវទម្រង់ចូលជាសមាជិក និងសេចក្ដីព្រាងលក្ខខ័ណ្ឌការងាររបស់បណ្ដាញសហគ្រិនស្ដ្រីនៅកម្ពុជា។

**ជ.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ច័ន្ទ សុរិយ៍**

សម្រាប់ព័ត៌មានបន្ថែម៖
- ហ្វេសប៊ុក: ministry of women's affairs of cambodia
- 077 871418/016 691167

ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ៨៨០ ៧៣៧ / ៨៨២ ០៤៨
៨៨២ ០៣៩ / ៨៨២ ០៤៩
ទូរសារ : ០២៣ ៨៨០ ៧៣៧